# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Oct-2011, 15:22
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

# សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការប្រជុំមួយស្តីពីការរៀបចំសវនាការ និង ការប្រជុំទៀងទាត់នានាស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង០០២

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សុវាន
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់កាលវិភាគសម្រាប់ឱ្យមានការប្រជុំរៀបចំសវនាការមួយ ដោយអនុលោមតាមវិធាន ៧៩.៧ នៃវិធានផ្ទៃក្នុង នៅក្នុងរយៈពេលចំនួនពីរសប្តាហ៍ខាងមុខនេះ និងស្នើសុំបន្ថែមទៀតឱ្យមានការប្រជុំប្រចាំសប្តាហ៍ស្តីពីស្ថានភាពសវនាការរវាងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ជាមួយនឹងតំណាងនានារបស់ភាគីទាំងឡាយ ដោយចាប់ផ្តើមពីសប្តាហ៍ទី ២៤ តុលា ២០១១ នេះតទៅ។ ការប្រជុំទាំងនេះត្រូវបានស្នើឡើងដើម្បីផ្តល់នូវយន្តការមួយបន្ថែមទៀតសម្រាប់ភាគីនានា ដើម្បីប្រាស្រ័យទាក់ទងគ្នាអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅនៃសវនាការដ៏ត្រឹមត្រូវ និងដោយឆាប់រហ័ស។

## II. ការប្រជុំរៀបចំសវនាការ

២. ដោយឡែក សំណើស្នើសុំឱ្យមានការប្រជុំរៀបចំសវនាការ គឺដើម្បីជួយឱ្យសហព្រះរាជអាជ្ញា ហើយអាចនឹងជួយដល់ភាគីនានាផងដែរ ឱ្យមានមានលទ្ធភាពដើម្បីស្វែងរកនូវការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលបានចេញនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ហើយនិង ដីកាកំណត់កាលបរិច្ឆេទ និងកិច្ចដំណើរការនីតិវិធី ដែលបានចេញនៅក្នុងសប្តាហ៍ ១៨ តុលា ២០១១[1]។ ដីកាសម្រេច និងដីកាកំណត់ទាំងនេះ មានឥទ្ធិពលទៅលើវចនាសម្ព័ន្ធនៃសវនាការ និងនីតិវិធីភស្តុតាងដែលត្រូវអនុវត្ត។ ការបញ្ជាក់ទាំងនេះជាតម្រូវការដើម្បីជួយដល់សហព្រះរាជអាជ្ញា នៅក្នុងការត្រៀមរៀបចំសវនាការ។

៣. ការបញ្ជាក់នានាដែលត្រូវស្វែងរក និង បញ្ហានានាដែលសហព្រះរាជអាជ្ញាចង់លើកឡើងនៅក្នុងការប្រជុំរៀបចំសវនាការនោះ រួមមាន៖

---

[1] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង, ថ្ងៃទី២២ កញ្ញា ២០១១។ **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និង សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ថ្ងៃទី១៨ តុលា ២០១១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនគ្រប់ភាគីទាំងអស់, សំណុំរឿង ០០២, កម្មវត្ថុស្តីពីបញ្ជីឈ្មោះសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង, កាលបរិច្ឆេទកំណត់សម្រាប់ការដាក់ឯកសារស្តីពីភាពអាចទទួលយកបាននូវឯកសារ និងវត្ថុតាង, និង ចម្លើយតបទៅនឹងសំណើលេខ E109/5, ថ្ងៃទី១៨ តុលា ២០១១ (សំណៅដោយការគួរសមដែលផ្ញើដោយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់)។ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យពិចារណាឡើងវិញលើពាក្យពេជន៍នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (E124/2) ហើយនឹងសំណើ និងឧបសម្ព័ន្ធពាក់ព័ន្ធនានា, ថ្ងៃទី១៨ តុលា ២០១១។ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យពិចារណាឡើងវិញលើពាក្យពេជន៍នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (E124/2) ហើយនិងសំណើ និងឧបសម្ព័ន្ធពាក់ព័ន្ធនានា, ថ្ងៃទី១៨ តុលា ២០១១។ **E124/7.1** ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និង ផ្នែកនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងសវនាការដំបូងក្នុងសំណុំរឿង ០០២, ថ្ងៃទី១៨ តុលា ២០១១។

(១) ចរឹតលក្ខណៈ និង វិសាលភាពនៃការជូនដំណឹង ដើម្បីដាក់បញ្ចូលនូវបទចោទ ទៅនឹងសវនាការដំបូង។
(២) ប្រភេទ ចំនួន និង លំដាប់លំដោយនៃសាក្សីដែលគេឲ្យឡើងសវនាការ។
(៣) ពេលវេលាដែលអង្គជំនុំជម្រះសាលាដំបូងបែងចែកដល់ភាគីនានាឲ្យសួរជនជាប់ចោទ និងសាក្សីនានា។
(៤) ការបង្ហាញជូននូវភស្តុតាងជាឯកសារសំរាប់ការទទួលយក នៅមុនពេល ឬនៅក្នុងចន្លោះពេល នៃការធ្វើសក្ខីកម្មរបស់ជនជាប់ចោទ ឬសាក្សី។
(៥) វិសាលភាពដែលអាចអនុញ្ញាតបាននៃការពិនិត្យលើគោលនយោបាយផ្សេងៗ និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលនយោបាយទាំងនោះ ក្រៅពីការជម្លៀសចេញដោយបង្ខំ។
(៦) សំនួរអំពីថាតើជនជាប់ចោទនឹងផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការជំនុំជម្រះក្តី ឬអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់ខ្លួនដែរ ឬទេ?។
(៧) នីតិវិធីនានាទាក់ទងនឹងការអនុញ្ញាតដើម្បីធ្វើការឆ្លើយតបទៅនឹងចម្លើយតបនានា ដើម្បីធានាឲ្យប្រាកដថាកំណត់ហេតុពេញលេញមួយរបស់តុលាការត្រូវបានរក្សាទុក។
(៨) បញ្ហាស្តីពីការថ្លឹងថ្លែងអំពីអាទិភាពនៃការបកប្រែរវាងភាគីនានា និងអង្គជំនុំជម្រះ។ និង
(៩) បញ្ហាដែលពាក់ព័ន្ធផ្សេង"ទៀត។

## III. ការប្រជុំទៀងទាត់ស្តីពីស្ថានភាពនៃសវនាការ

៤. ជាបន្ថែមពីលើនេះ សហព្រះរាជអាជ្ញា សូមស្នើដល់ អង្គជំនុំជម្រះសាលាដំបូង សុំឲ្យចាត់តាំងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ចំនួនមួយរូប ដើម្បីឲ្យធ្វើការកោះប្រជុំតាមការកំណត់ជាទៀងទាត់មួយជាមួយនឹងតំណាងរបស់ភាគីនានា ដែលនៅក្នុងកិច្ចប្រជុំទាំងនោះ បញ្ហាផ្សេងៗអាចនឹងត្រូវបានលើកឡើង និងដើម្បីស្វែងរកការបំភ្លឺលើបញ្ហាដែលមានភាពស្មុគស្មាញ និងដែលកំពុងតែវិវឌ្ឍន៍ ដែលបានកើតមានឡើងចាប់តាំងពីពេលមានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដីកាសំរេចស្តីពីការកំណត់កាលបរិច្ឆេទនៃសវនាការមក ហើយដែលជាប់ទាក់ទងទៅនឹងសេចក្តីសំរេចនានា ក៏ដូចជាសេចក្តីសម្រេចទាំងឡាយដែលទំនងជានឹងលេចឡើង នៅបន្ទាប់ពីដំណើរការសវនាការ ដែលមានសារៈសំខាន់បានចាប់ផ្តើម។

៥. កិច្ចប្រជុំដូច្នេះ ទោះបីជាពុំមានចែងច្បាស់លាស់នៅក្នុងវិធានរបស់ អ.វ.ត.ក ក៏ដោយ គឺជាផ្នែកនៃនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) អនុលោមតាមវិធាន ៦៥*ស្ទួនពីរ* ឃ(iii) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ខ្លួន (RoPE) ដែលអនុញ្ញាតឲ្យមានកិច្ចពិភាក្សាដែលមានលក្ខណៈមិនសូវជាផ្លូវការ និងធ្វើឡើងឲ្យបានញឹកញាប់ ដើម្បីជួយសម្រួលដល់សវនាការមួយមានភាពត្រឹមត្រូវ និងឆាប់រហ័ស។

(iii) ដោយអនុវត្តតាមការចង្អុលបង្ហាញរបស់ចៅក្រមមុនសវនាការ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកិច្ចការច្បាប់ត្រូវពិនិត្យមើលការអនុវត្តផែនការការងារ និងត្រូវជម្រាបជូនចៅក្រមមុនសវនាការជាប្រចាំអំពីការរីកចម្រើននៃកិច្ចពិភាក្សាផ្សេងៗរវាង និងជាមួយនឹងគូភាគីនានា និងជាពិសេស អំពីការលំបាកដ៏មានសក្តានុពលណាមួយ។ មន្ត្រីរូបនេះ ត្រូវបង្ហាញជូនចៅក្រមមុនសវនាការ នូវរបាយការណ៍ផ្សេងៗតាមការសមស្រប និងត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយគូភាគីនានា អំពីសេចក្តីសង្ខេត និងសេចក្តីសម្រេចណាមួយ ដែលបានធ្វើឡើងដោយចៅក្រមមុនសវនាការ ដោយពុំមានការពន្យារពេល។

៦. កិច្ចប្រជុំទាំងនេះ នឹងអនុញ្ញាតឲ្យគូភាគីបានធ្វើការប្រាស្រ័យទាក់ទងគ្នាកាន់តែញឹកញាប់និងកាន់តែមានប្រសិទ្ធិភាពជាមួយអង្គជំនុំជម្រះមុនសវនាការ និងដើម្បីជួយសម្រួលដល់ការរីកចម្រើននៃកិច្ចដំណើរការនីតិវិធីឲ្យប្រព្រឹត្តទៅដោយរលូន និងដើម្បីជៀសវាងការពន្យារពេល។ នៅក្នុងកិច្ចប្រជុំទាំងនេះ សេចក្តីបញ្ជាក់បំភ្លឺ ឬ កង្វល់ផ្សេងៗអំពីបញ្ហាសំខាន់ៗ និងបញ្ហាពាក់ព័ន្ធនីតិវិធីដទៃទៀតរបស់សវនាការ អាចនឹងត្រូវបានលើកមកពិភាក្សាក្នុងលក្ខណៈមួយកាន់តែលម្អិត ប៉ុន្តែតាមរបៀបមួយដែលមានលក្ខណៈមិនសូវជាផ្លូវការ ជាងក្នុងពេលសវនាការលើអង្គសេចក្តី ឬតាមញត្តិលាយលក្ខណ៍អក្សរ ឬ អ៊ីម៉ែល។ កិច្ចប្រជុំទាំងនេះ ក៏នឹងបញ្ចៀសឬកាត់បន្ថយនូវកិច្ចពិភាក្សាដេញដោលដែលស៊ីពេលច្រើននៅក្នុងអង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហាផ្សេងៗផងដែរ ដែលការណ៍នេះនឹងរក្សាពេលវេលាសម្រាប់សវនាការលើភស្តុតាង និងអំណះអំណាងច្បាប់ជាសារធាតុ។

## IV. ដំណោះស្រាយដែលស្នើឡើង

៧. ដូចមូលហេតុរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើថា កិច្ចប្រជុំរៀបចំសវនាការ និងកិច្ចប្រជុំទៀងទាត់ប្រចាំសប្តាហ៍ស្តីពីស្ថានភាពសវនាការ នឹងត្រូវបានធ្វើឡើងដើម្បីជួយដល់សហព្រះរាជអាជ្ញា និងភាគីនានា ក្នុងការត្រៀមរៀបចំសម្រាប់សវនាការឲ្យកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល ហើយក៏ជួយដល់អង្គជំនុំជម្រះសាលាដំបូងតាមភារកិច្ចរបស់ខ្លួន ដើម្បីធានាថាសវនាការនេះមានភាពត្រឹមត្រូវ និងឆាប់រហ័ស ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ | **លោក យ៉ែត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |